ជស/រកម/០២៩៨/០៣

រដ្ឋសភា
ល លេខ......5...........
ថ្ងៃទី 14. 3. 98 ម៉ោង ...
បញ្ជូនទៅ ...

# ព្រះរាជក្រម

យើង

**ព្រះបាទសម្តេច ព្រះនរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធិវង្ស អគ្គមហាបុរសរតន៍ និករោត្តម**

**ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

* * * * * * * *

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២ នស.៩៤ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ ១៩៩៤ ស្តីពី ការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត.១០៩៥.៩០ ចុះថ្ងៃទី ៣១ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត.០៨៩៧.១៨៧ ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ១៩៩៧ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០១ នស ៩៣ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ១៩៩៣ ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស.រកម.០១៩៦.១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស.រកម.០២៩៧.០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ ស្តីពីសារពើពន្ធ
- តាមសេចក្តីក្រាបបង្គំទូលរបស់សម្តេចនាយករដ្ឋមន្ត្រីទី១និងឯកឧត្តមនាយករដ្ឋមន្ត្រីទី២ និងទេសរដ្ឋមន្ត្រី ទទួលបន្ទុកនីតិសម្បទា និងអភិវឌ្ឍន៍ និងជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## ប្រកាសឲ្យប្រើ

ច្បាប់ស្តីពី របបហិរញ្ញវត្ថុនិងទ្រព្យសម្បត្តិរបស់ខេត្ត ក្រុង ដែលរដ្ឋសភាបានអនុម័ត កាលពីថ្ងៃទី១០ ខែ កុម្ភៈ ឆ្នាំ១៩៩៨ ក្នុងសម័យប្រជុំលើកទី៨ នីតិកាលទី១ ដែលមានសេចក្តីទាំងស្រុងដូចតទៅ :

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

-----------------

រដ្ឋសភា

# ច្បាប់

# ស្តីពី

# របបហិរញ្ញវត្ថុនិងទ្រព្យសម្បត្តិរបស់ខេត្ត ក្រុង

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ច្បាប់នេះមានគោលដៅកំណត់នូវរបបហិរញ្ញវត្ថុរបស់ខេត្ត ក្រុងនិងការគ្រប់គ្រងទ្រព្យសម្បត្តិដែលរដ្ឋប្រគល់ឱ្យខេត្ត ក្រុងកាន់កាប់ ។

**មាត្រា ២.-**

ខេត្ត ក្រុងគឺជានីតិបុគ្គលស្ថិតនៅក្នុងក្របខ័ណ្ឌនៃនីតិសាធារណៈ ។

ខេត្ត ក្រុងបំពេញនូវសមត្ថកិច្ចនានាដែលច្បាប់អនុញ្ញាត មានថវិកានិងមានទ្រព្យសម្បត្តិទាំងឡាយដែលកំណត់ដោយច្បាប់នេះ ។

**មាត្រា ៣.-**

ខេត្ត ក្រុង ត្រូវគ្រប់គ្រងដោយអភិបាលមួយរូបនិងអភិបាលរងមួយចំនួនជាជំនួយការនៅក្នុងលក្ខខណ្ឌដែលត្រូវកំណត់ដោយច្បាប់ ។

**មាត្រា ៤.-**

អភិបាលខេត្ត ក្រុងគឺជាតំណាងនៃរដ្ឋបាលកណ្តាលនៅក្នុងមណ្ឌលដែនដីរបស់ខ្លួន ។

នៅក្នុងវិស័យហិរញ្ញវត្ថុ អភិបាលខេត្ត ក្រុងជាអ្នកទទួលអនុវត្តបន្តនូវអំណាចរបស់រដ្ឋនិងស្ថិតនៅក្រោមការគ្រប់គ្រងនៃរដ្ឋមន្ត្រីសមត្ថកិច្ច ។ ចំពោះរដ្ឋបាលសាធារណៈទូទៅ អភិបាលខេត្ត ក្រុងមានភារកិច្ចក្នុងការសំរបសំរួល តម្រង់ទិសដៅ ជំរុញនិងតាមដានការអនុវត្ត ។

## ជំពូកទី ២
## សមត្ថកិច្ចនិងការគ្រប់គ្រងហិរញ្ញវត្ថុនិងទ្រព្យសម្បត្តិរបស់ខេត្ត ក្រុង

**មាត្រា ៥.-**

ខេត្ត ក្រុងទទួលបន្ទុកគ្រប់គ្រងកិច្ចការជាគុណប្រយោជន៍ក្នុងមណ្ឌលដែនដីរបស់ខ្លួនដើម្បីធានាអោយសេវាសាធារណៈ ដែលមិនស្ថិតនៅក្រោមការទទួលខុសត្រូវផ្ទាល់របស់រដ្ឋ ឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋក្នុងខេត្ត ក្រុង ។ សមត្ថកិច្ចរបស់ខេត្ត ក្រុងត្រូវកំណត់ដោយអនុក្រឹត្យតាមសំណើរួមរបស់ក្រសួងមហាផ្ទៃនិងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

**មាត្រា ៦.-**

ចំពោះវិស័យហិរញ្ញវត្ថុនិងនៅក្នុងក្របខ័ណ្ឌនៃបទប្បញ្ញត្តិទាំងឡាយក្នុងជំពូកទី ៤ នៃច្បាប់នេះ អភិបាលខេត្ត ក្រុងជាអ្នករៀបចំថវិការបស់ខេត្ត ក្រុង ។ ក្នុងការអនុវត្តថវិកានេះ អភិបាលខេត្ត ក្រុងជាអ្នកគ្រប់គ្រងក្នុងឋានៈជាអាណាប័កដើមខ្សែនិងជាអ្នកបង្កើតនិងបិទនូវគណនីរដ្ឋបាល ។

អភិបាលខេត្ត ក្រុងធ្វើសំណើទៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុអំពីចំណូលសារពើពន្ធនិងពុំមែនសារពើពន្ធនៅក្នុងក្របខ័ណ្ឌនៃប្រព័ន្ធសារពើពន្ធ និងពុំមែនសារពើពន្ធ ដើម្បីជាគុណប្រយោជន៍របស់ខេត្ត ក្រុងនិងតាមដានជំរុញនូវការប្រមូលចំណូលទាំងនោះ ។

**មាត្រា ៧.-**

អភិបាលខេត្ត ក្រុងគ្រប់គ្រងទ្រព្យសម្បត្តិសាធារណៈនៅក្នុងមណ្ឌលដែនដីរបស់ខ្លួន។ អភិបាលខេត្ត ក្រុងគ្រប់គ្រងនិងថែរក្សានូវទ្រព្យសម្បត្តិទាំងឡាយដែលរដ្ឋប្រគល់អោយខេត្ត ក្រុងកាន់កាប់ នៅក្នុងក្របខ័ណ្ឌនៃច្បាប់និងបទបញ្ញាជាធរមាន ។

**មាត្រា ៨.-**

របបហិរញ្ញវត្ថុនិងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់ខេត្ត ក្រុងត្រូវស្ថិតនៅក្រោមអាណាព្យាបាលនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។ លក្ខខណ្ឌគ្រប់គ្រងនៃអាណាព្យាបាលនេះ ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបន្ទាប់ពីមានយោបល់ឯកភាពពីក្រសួងមហាផ្ទៃ ។

## ជំពូកទី ៣

## ទ្រព្យសម្បត្តិរបស់ខេត្ត ក្រុង

**មាត្រា ៩.-**

រដ្ឋប្រគល់អោយខេត្ត ក្រុងនីមួយៗនូវសិទ្ធិកាន់កាប់និងសិទ្ធិប្រើប្រាស់ទ្រព្យសម្បត្តិសាធារណៈអចលនវត្ថុមួយចំនួនដែលស្ថិតនៅក្នុងមណ្ឌលដែនដីនៃខេត្ត ក្រុងទៅតាមការកំណត់របស់រដ្ឋ ។

ការប្រគល់នេះ ត្រូវបានសំរេចដោយប្រកាសរួមរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនិងក្រសួងមហាផ្ទៃដោយមានហត្ថលេខាទទួលអនុវត្តរបស់អភិបាលខេត្ត ក្រុង ។

ការប្រគល់ត្រូវបានប្រតិបត្តិក្នុងលក្ខណៈ ដែលអាចដកហូតយកវិញបាន ។

អភិបាលខេត្ត ក្រុងដែលជាអាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរដ្ឋត្រូវទទួលបន្ទុកថែរក្សានិងជួសជុលនូវទ្រព្យសម្បត្តិរដ្ឋទាំងនោះ ។ អភិបាលខេត្ត ក្រុងត្រូវបាននូវការគ្រប់គ្រងនិងអាច

ទទួលបាននូវផលទុនដែលបានមកពីទ្រព្យសម្បត្តិទាំងនោះ បន្ទាប់ពីមានការយល់ព្រមរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនិងតាមយោបល់ឯកភាពពីក្រសួងមហាផ្ទៃ ។ អភិបាលខេត្ត ក្រុងមិនអាចផ្តល ផ្ទេរការប្រើប្រាស់ទ្រព្យសម្បត្តិទាំងនោះដោយគ្មានការយល់ព្រមជាមុនពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បន្ទាប់ពីមានយោបល់ឯកភាពពីក្រសួងមហាផ្ទៃឡើយ ។

**មាត្រា ១០.-**

រដ្ឋអាចប្រគល់ដើម្បីជាគុណប្រយោជន៍របស់ខេត្ត ក្រុង នូវអាគារនិងសមិទ្ធផលដែលមានគោលបំណងដើមសម្រាប់ការប្រើប្រាស់សាធារណៈ ឬសម្រាប់បំពេញនូវតម្រូវការនៃសេវាសាធារណៈ ។

**មាត្រា ១១.-**

ទ្រព្យសម្បត្តិអចលនវត្ថុនិងចលនវត្ថុសំរាប់សេវាសាធារណៈ ដែលខេត្ត ក្រុងរកបានដោយខ្លួនឯងគឺជាកម្មសិទ្ធិរបស់ខេត្ត ក្រុងផ្ទាល់ ។

# ជំពូកទី ៤

## ថវិការបស់ខេត្ត ក្រុង

## ផ្នែកទី ១

## បន្ទុកនិងធនធានរបស់ខេត្ត ក្រុង

**មាត្រា ១២.-**

ថវិការបស់ខេត្ត ក្រុងត្រូវស្ថិតនៅក្រោមបទប្បញ្ញត្តិទាំងឡាយនៃច្បាប់ស្តីអំពីប្រពន្ធ័ហិរញ្ញវត្ថុដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ០១ នស.៩៣ ចុះថ្ងៃទី ២៨ ខែធ្នូ ឆ្នាំ១៩៩៣ ។

**មាត្រា ១៣.-**

ថវិការបស់ខេត្ត ក្រុងត្រូវតែមានតុល្យភាពរវាងចំណូលនិងចំណាយ ។ គំរោងចំណូលនិងចំណាយត្រូវតែរៀបចំនិងអនុម័តដោយមានតុល្យភាពពិតប្រាកដ ក្នុងនោះត្រូវគិតទាំងកិច្ចសន្យានៃការគ្រប់គ្រងពីមុនផង ។

**មាត្រា ១៤.-**

ចំណាយចាំបាច់របស់ខេត្ត ក្រុង មានដូចតទៅ ៖

១-ថ្លៃសំណុំថែទាំទីស្នាក់ការរបស់ខេត្ត ក្រុងឬការផ្តល់ផ្ទះឬបន្ទប់បើសិនជាមាន

២-សោហ៊ុយចំណាយថែរក្សាសារលិខិតនិងឯកសារទាំងឡាយដែលជាបន្ទុករបស់ខេត្ត ក្រុង ។

៣-ចំណាយប្រាក់បៀវត្សនិងប្រាក់បំណាច់របស់បុគ្គលិកដែលស្ថិតនៅក្នុងបន្ទុករបស់ខេត្ត ក្រុងផ្ទាល់និងក្រោកឧបត្ថម្ភភូមិ ឃុំ សង្កាត់ ។

៤-សោហ៊ុយចំណាយដំណើរការរបស់សេវារដ្ឋបាលដែលស្ថិតនៅក្រោមសមត្ថកិច្ចរបស់ខេត្ត ក្រុង ព្រមទាំងសេវាសាធារណៈមានជាអាទិ៍ដូចជា ការបំភ្លឺសាធារណៈ ការប្រឆាំងនឹងអគ្គីភ័យ ការប្រមូលសំរាមនិងអន្តរាគមន៍ក្នុងវិស័យជំនួយសង្គមកិច្ច អនាម័យ សុខាភិបាល ។

៥-ចំណាយសំរាប់ការរៀបចំ ការថែទាំនិងការជួសជុលធំនូវសំណង់អាគារសាធារណៈ បរិក្ខារ សម្ភារៈគ្រប់ប្រភេទដែលរដ្ឋប្រគល់ឱ្យខេត្ត ក្រុងកាន់កាប់មានជាអាទិ៍ដូចជា អាគាររដ្ឋបាល អាគារសិក្សា មន្ទីរពេទ្យ ទីផ្សារសាធារណៈ បរិក្ខារកីឡា វប្បធម៌ ។

៦-សោហ៊ុយចំណាយថែទាំផ្លូវថ្នល់ សួនច្បារសាធារណៈនិងចំណាយសំរាប់ការរៀបជាផ្លូវ។

៧-សោហ៊ុយចំណាយថែទាំប្រឡាយលូទឹក អណ្តូងទឹក ក្បាលម៉ាស៊ីនទឹក ប្រឡាយបញ្ចេញទឹកមិនស្អាតឬទឹកភ្លៀង ។

៨-ចំណាយទាំងឡាយណាដែលស្ថិតនៅក្នុងបន្ទុករបស់ខេត្ត ក្រុងដែលច្បាប់ឬបទបញ្ញាបានកំណត់ ។

**មាត្រា ១៥.-**

ក្រៅពីចំណាយទាំងឡាយដែលបានរៀបរាប់ក្នុងមាត្រា ១៤ នៃច្បាប់នេះ ខេត្ត ក្រុងអាចមានចំណាយបន្ទាប់បន្សំនិងមានកំរិតមានជាអាទិ៍ដូចជា សោហ៊ុយចំណាយទទួលភ្ញៀវ ប្រជុំទស្សនកិច្ច ។ ខ្ទង់ចំណាយទាំងនោះអាចគ្រោងបានតែនៅក្នុងករណីដែលមិនប៉ះពាល់ដល់ចំណាយចាំបាច់និងមិនធ្វើអោយបាត់តុល្យភាពថវិកា ។

**មាត្រា ១៦.-**

គ្រប់គំរោងវិនិយោគដែលមានទឹកប្រាក់ស្មើឬលើសពីចំនួនទឹកប្រាក់ដែលបានកំណត់ដោយប្រកាសអាចបញ្ចូលនៅក្នុងថវិកាខេត្ត ក្រុងបាន លុះត្រាតែមានការយល់ព្រមជាមុនពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

**មាត្រា ១៧.-**

ចំណូលនៃថវិកាសំរាប់ការប្រព្រឹត្តទៅរបស់ខេត្ត ក្រុងត្រូវបានផ្គត់ផ្គង់ដោយចំណូលសារពើពន្ធនិងពុំមែនសារពើពន្ធ ដែលបានមកពីថវិការដ្ឋឬបង្កើតឡើងដោយឡែកសំរាប់ជាគុណប្រយោជន៍ខេត្ត ក្រុង ។ ខេត្ត ក្រុងគ្មានសិទ្ធិសំរេចផ្តល់ការខ្ចីទេ ។

១-ត្រូវបានផ្ទេរពីថវិការដ្ឋទៅឱ្យថវិការបស់ខេត្ត ក្រុងនូវចំណូលសារពើពន្ធនិងពុំមែនសារពើពន្ធដូចតទៅ :

ក-<u>ចំណូលសារពើពន្ធ:</u>

-ជំពូក១០-០៨ : ពន្ធលើដីធ្លីមិនបានប្រើប្រាស់

-ជំពូក១១-០១ : ពន្ធប្រថាប់ត្រា

-ជំពូក១២-០៣ : ពន្ធប៉ាតង់

-ជំពូក១២-០៥ : ពន្ធសណ្ឋាគារ

-ជំពូក១២-០៦ : ពន្ធលើមធ្យោបាយដឹកជញ្ជូននិងយានជំនិះគ្រប់ប្រភេទ

ខ-<u>ចំណូលពុំមែនសារពើពន្ធ:</u>

-ជំពូក២០-០៣-១៣ : ចំណូលពីការផ្គត់ផ្គង់អគ្គីសនីនៅតាមខេត្ត ក្រុង

-ជំពូក២០-០៣-១៤ : ផលខុននៃរដ្ឋាករទឹកនៅតាមខេត្ត ក្រុង

-ជំពូក២០-០៥ : ចំណូលពីការកាន់កាប់ទ្រព្យសម្បត្តិសាធារណៈ ( ផ្សារ ចំណតរថយន្ត កំពង់ផែ កន្លែងលក់ដេញថ្លៃ )

-ជំពូក២១-០៥ : ចំណូលពុំមែនសារពើពន្ធផ្សេងៗទៀតរបស់ខេត្ត ក្រុង

២-មាតិកានៃចំណូលផ្ទាល់ពីសារពើពន្ធសំរាប់ជាគុណប្រយោជន៍របស់ខេត្ត ក្រុងត្រូវបង្កើតឡើងដោយច្បាប់ដោយឡែក ។

៣-មាតិកានៃចំណូលពុំមែនសារពើពន្ធសំរាប់ជាគុណប្រយោជន៍ខេត្ត ក្រុងមានដូចតទៅ :

ក-ចំណូលសំរាប់ទំរង់ការរដ្ឋបាលដែលកើតឡើងដោយសារការប្រើអំណាចរបស់ខេត្ត ក្រុងតាមច្បាប់បញ្ជាក់លើហត្ថលេខា បញ្ជាក់លើលិខិតចម្លងតាមច្បាប់ដើម វិញ្ញាបនប័ត្រដទៃទៀតនិងលិខិតផ្សេងៗ

ខ-ចំណូលសំរាប់ការអនុញ្ញាតរដ្ឋបាល

គ-ចំណូលសំរាប់សេវាកម្មសាធារណៈដែលប្រភេទនិងអត្រារបស់វាទាក់ទងទៅនឹងអត្ថប្រយោជន៍ពិតដែលបានធានាអះអាងដោយខេត្ត ក្រុងចំពោះអ្នកប្រើប្រាស់ ។

ចំណូលទាំងនេះត្រូវកំណត់ដោយអនុក្រឹត្យរបស់រាជរដ្ឋាភិបាល យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនិងតាមយោបល់ឯកភាពរបស់ក្រសួងដែលពាក់ព័ន្ធដែលនឹងត្រូវចែងជាតារាងយកចំណូលជាអតិបរមា ។

## ផ្នែកទី២

## ការរៀបចំនិងការអនុម័តថវិការបស់ខេត្ត ក្រុង

**មាត្រា ១៨.-**

គំរោងថវិការបស់ខេត្ត ក្រុងត្រូវបានរៀបចំឡើងដោយអភិបាលខេត្ត ក្រុងទៅតាមនីតិវិធីដែលបានកំណត់ដោយប្រកាសរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

គំរោងថវិការបស់ខេត្ត ក្រុងត្រូវបញ្ជូនមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុយ៉ាងយឺតបំផុតត្រឹមថ្ងៃទី ០១ ខែកញ្ញានៃឆ្នាំនីមួយៗដោយភ្ជាប់មកជាមួយនូវកំណត់បង្ហាញដែលវិភាគពីគោលដៅកម្មវិធីនិងចរិតលក្ខណៈនៃថវិកា ព្រមទាំងលិខិតយុត្តិការចាំបាច់ ។

គំរោងថវិការបស់ខេត្ត ក្រុងទាំងអស់គឺជាកញ្ចប់ថវិកាមួយដែលត្រូវបញ្ជូនមកសុំរដ្ឋ-សភាពិនិត្យអនុម័តយល់ព្រមក្នុងក្របខ័ណ្ឌថវិកាទូទៅរបស់រដ្ឋនិងត្រូវរក្សានូវតុល្យភាពសេដ្ឋកិច្ចជាមូល-ដ្ឋាន ។ ការបែងចែកកញ្ចប់ថវិកានេះទៅតាមខេត្ត ក្រុងនីមួយៗត្រូវធ្វើឡើងតាមប្រកាសរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បន្ទាប់ពីបានទទួលយោបល់ឯកភាពពីក្រសួងមហាផ្ទៃ ។

**មាត្រា ១៩.-**

ឥណទានដែលបានបំរុងទុករបស់រដ្ឋសំរាប់កម្មវិធីអភិវឌ្ឍន៍ខេត្ត ក្រុងនិងសំរាប់គំរោងដែលមានលក្ខណៈខេត្ត ក្រុងត្រូវបានផ្ទេរទៅអោយថវិការបស់ខេត្ត ក្រុងនិងត្រូវចាត់ទុកដូចជាប្រភពធនធាននិងចំណាយផ្ទាល់ដោយអនុលោមទៅតាមច្បាប់ហិរញ្ញវត្ថុ ។

## ផ្នែកទី ៣

## ការអនុវត្តនិងបទបញ្ជានៃថវិការបស់ខេត្ត ក្រុង

**មាត្រា ២០.-**

ថវិការបស់ខេត្ត ក្រុងអាចកែប្រែបានក្នុងឆ្នាំដោយអនុលោមទៅតាមលក្ខខណ្ឌដូចគ្នាដែលមានចែងនៅក្នុងច្បាប់ស្ដីអំពីប្រព័ន្ធហិរញ្ញវត្ថុ ។

**មាត្រា ២១.-**

ចលនាឥណទានផ្ទៃក្នុងថវិការបស់ខេត្ត ក្រុងត្រូវធ្វើឡើងក្នុងលក្ខខណ្ឌដែលកំណត់ដោយប្រកាសរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

**មាត្រា ២២.-**

កាលណាការអនុវត្តថវិការបស់ខេត្ត ក្រុងធ្វើអោយលេចចេញនូវឱនភាពហើយមិនបានដាក់ចេញនូវវិធានការគ្រប់បែបយ៉ាងនោះ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសំរេចថវិកានោះ តែម្តង ដើម្បីបាននូវតុល្យភាពថវិកាឡើងវិញ ។ តែឱ្យយកទៅវិញ នៅបំណាច់ឆ្នាំនីមួយៗបើថវិការបស់ខេត្ត ក្រុងមានចំនួនលើសត្រូវតែបង់ចូលថវិការដ្ឋ ។

**មាត្រា ២៣.-**

ការអនុវត្តថវិការបស់ខេត្ត ក្រុងស្ថិតនៅក្រោមបទប្បញ្ញត្តិទាំងឡាយដែលអនុវត្តចំពោះថវិកាទូទៅរបស់រដ្ឋ ។ កិច្ចប្រតិបត្តិការហិរញ្ញវត្ថុនិងគណនេយ្យត្រូវប្រតិបត្តិទៅតាមវិធានទាំងឡាយមានជារាគី ស្តីពីបទបញ្ញាទូទៅនៃគណនេយ្យសាធារណៈ ស្តីពីការបង្កើតការត្រួតពិនិត្យហិរញ្ញវត្ថុលើការចំណាយថវិការដ្ឋនៅតាមក្រសួង ខេត្ត ក្រុង ក្រុងស្វយ័ត រាជធានីភ្នំពេញនិងអង្គការសាធារណៈរដ្ឋបាល ស្តីពីការគ្រប់គ្រងលទ្ធកម្មសាធារណៈ ។

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុត្រូវចេញប្រកាសដើម្បីកំណត់នូវលក្ខខណ្ឌអនុវត្តនៃវិធានទាំងនេះសំរាប់ខេត្ត ក្រុង។

មុខងារគណនេយ្យរបស់ខេត្ត ក្រុងត្រូវកាន់កាប់ដោយគណនេយ្យកររម្នាក់របស់រតនាគារ ដែលតែងតាំងឡើងដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

## ជំពូកទី ៥

## ការគ្រប់គ្រងសេវាសាធារណៈរបស់ខេត្ត ក្រុង

**មាត្រា ២៤.-**

ខេត្ត ក្រុងត្រូវរៀបចំនីតិវិធីគ្រប់គ្រងសេវាសាធារណៈនៅក្នុងមណ្ឌលដែនដីរបស់ខ្លួន ។

**មាត្រា ២៥.-**

បន្ទាប់ពីមានយោបល់ឯកភាពពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុអនុញ្ញាតឱ្យខេត្ត ក្រុងធ្វើអាជីវកម្មផ្ទាល់នូវសេវាសាធារណៈក្រោមរូបភាពជារដ្ឋាករ ឬដកហូតមកវិញនូវការអនុញ្ញាតនោះ ។ ការចាត់តាំងរដ្ឋបាល របបហិរញ្ញវត្ថុនិងការប្រព្រឹត្តទៅនៃរដ្ឋាករត្រូវកំណត់ដោយអនុក្រឹត្យតាមសំណើរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

ចំណូលនិងចំណាយនៃរដ្ឋាករត្រូវកត់ត្រាបញ្ចូលក្នុងថវិការបស់ខេត្ត ក្រុង ។ គណនេយ្យករខេត្ត ក្រុងត្រូវកុះកិច្ចបញ្ជីកាចំណូលនិងចំណាយទាំងនោះ ដោយអនុលោមទៅតាមបទបញ្ញាជាធរមាន

នៅក្នុងគណនេយ្យរបស់ខេត្ត ក្រុង។ ប៉ុន្តែខេត្ត ក្រុងអាចស្នើឱ្យសេវាសាធារណៈខ្លះដែលធ្វើអាជីវកម្ម ជារដ្ឋាករមានថវិកាស្វយ័ត ។ កាលបើសេវាសាធារណៈទាំងនេះមិនទាន់ធ្វើអាជីវកម្មជារដ្ឋាករទេ អាចអនុញ្ញាតអោយធ្វើសម្បទាន ។

**មាត្រា ២៦.-**

ខេត្ត ក្រុងអាចបង្កើតសហគ្រាសសាធារណៈមានលក្ខណៈឧស្សាហកម្មនិងពាណិជ្ជកម្ម សំរាប់គ្រប់គ្រងសេវាសាធារណៈមានលក្ខណៈឧស្សាហកម្មនិងពាណិជ្ជកម្មនៅក្នុងមណ្ឌលដែនដីរបស់ខ្លួន ។ ការរៀបចំនិងការប្រព្រឹត្តទៅនៃសហគ្រាសសាធារណៈទាំងនោះត្រូវអនុវត្តតាមច្បាប់និងបទបញ្ញាជាធរមាន ។

## ជំពូកទី ៦

## បុគ្គលិករបស់ខេត្ត ក្រុង

**មាត្រា ២៧.-**

អភិបាលខេត្ត ក្រុង តែងតាំងបុគ្គលិកខេត្ត ក្រុងក្នុងក្របខ័ណ្ឌថវិការបស់ខេត្ត ក្រុង ទៅតាមការកំណត់នៃលិខិតបទដ្ឋានដែលមានចែងជាធរមាន ក្រៅពីច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជាដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ០៦ ន.ស. ៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ។ ប៉ុន្តែបុគ្គលិកទាំងនេះត្រូវតែគោរពកាតព្វកិច្ចដែលតម្រូវចំពោះភ្នាក់ងារសាធារណៈទាំងអស់ ។

ការជ្រើសរើសបុគ្គលិកអោយចូលធ្វើការបានគឺកំរិតត្រឹមបុគ្គលិកប្រភេទ "គ" ឬ "ឃ" ដែលចាំបាច់បំផុត ក្រោយពីបានប្រើប្រាស់ឱ្យអស់លទ្ធភាពនូវមន្ត្រីរាជការដែលមានស្រាប់ ។

## ជំពូកទី ៧

## បទប្បញ្ញត្តិដោយឡែក

**មាត្រា ២៨.-**

បែបបទនៃការអនុវត្តច្បាប់នេះត្រូវកំណត់ឡើងដោយអនុក្រឹត្យ ផ្អែកតាមសភាពការណ៍ជាក់ស្តែងរបស់ខេត្ត ក្រុងនីមួយៗ និងដោយប្រកាសរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុទៅតាមការចាំបាច់ ។

# ជំពូកទី ៨

## អវសានប្បញ្ញត្តិ

**មាត្រា ២៩.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣០.-**

ច្បាប់នេះ ត្រូវបានប្រកាសជាការប្រញាប់ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ ១៩៩៨

ក្នុងព្រះបរមនាម និង តាមព្រះរាជបណ្ដាំ

ប្រមុខរដ្ឋស្ដីទី

**ហត្ថលេខា**

**ជា ស៊ីម**

បានយកសេចក្ដីក្រាបបង្គំទូលថ្វាយ .

សូមឡាយព្រះហស្ថលេខាព្រះមហាក្សត្រ

| **នាយករដ្ឋមន្ត្រីទី១** | **នាយករដ្ឋមន្ត្រីទី២** |
|---|---|
| **ហត្ថលេខា** | **ហត្ថលេខា** |
| **អ៊ុង ហួត** | **ហ៊ុន សែន** |

បានជំរាបជូន

ឯកឧត្ដមនាយករដ្ឋមន្ត្រីទី១និងសម្ដេចនាយករដ្ឋមន្ត្រីទី២

ទេសរដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការនីតិសម្បទា និង

អភិវឌ្ឍន៍និងជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

**ហត្ថលេខា**

**គាត ឈន់**

លេខ : ៧៤ ចល

**ដើម្បីចំលងចែក**

រាជធានីភ្នំពេញថ្ងៃទី ០២ ខែមីនា ឆ្នាំ១៩៩៨

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

... តាន់